ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ២១/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

**កិច្ចប្រជុំសង្ខេបព័ត៌មានអំពីការវិវត្តនៃសភាពការណ៍ព្រំដែនកម្ពុជា-ថៃ**
**ដោយលោកជំទាវ អ៊ិត សោភា**
**រដ្ឋមន្ត្រីស្តីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២៥ លោកជំទាវ **អ៊ិត សោភា** រដ្ឋមន្ត្រីស្តីទី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំកិច្ចប្រជុំសង្ខេបព័ត៌មាន ជូនដល់សមាជិកអង្គទូតបរទេស និងតំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំកម្ពុជា ស្តីពីការវិវត្តថ្មីៗនៃសភាពការណ៍ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

លោកជំទាវរដ្ឋមន្ត្រីស្តីទី បានផ្តល់ព័ត៌មានជាទូទៅអំពី**កិច្ចប្រជុំពិសេសស្តីពីស្ថានការណ៍រវាងកម្ពុជានិងថៃ** កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២៥ នៅទីក្រុងពុត្រាចាយ៉ា ប្រទេសម៉ាឡេស៊ី ដែលនាំឱ្យមានកិច្ចព្រមព្រៀងបទឈប់បាញ់។ លោកជំទាវបានធ្វើបច្ចុប្បន្នភាពបន្ថែមទៀតជូនដល់អ្នកចូលរួម អំពី**កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC)** នៅប្រទេសម៉ាឡេស៊ី ដែលបានបិទបញ្ចប់ដោយជោគជ័យ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០២៥ ដែលកិច្ចប្រជុំនេះបានជំរុញឱ្យមានវឌ្ឍនភាពអំពីការអនុវត្តបទឈប់បាញ់ និងជំហានដំបូង ដើម្បីឆ្ពោះទៅរកការស្តារប្រក្រតីភាព។

**លោកជំទាវរដ្ឋមន្ត្រីស្តីទី បានសម្តែងនូវក្តីកង្វល់យ៉ាងខ្លាំងរបស់កម្ពុជាចំពោះកំណើននៃការគំរាមកំហែងមកលើបទឈប់បាញ់ដែលផុយស្រួយ** ដោយលើកឡើងពីសកម្មភាពកំពុងប្រព្រឹត្តនានារបស់កងទ័ពថៃ រួមមានការចល័តទ័ព ការធ្វើផ្លូវនិងជីកលេណដ្ឋាន ដោយប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ ការប្រើប្រាស់ដ្រូនរំលោភចូលមកក្នុងដែនអាកាសកម្ពុជា ការបំផ្លិចបំផ្លាញផ្ទះសម្បែង និងការរាយលួសបន្លា និងដាក់របាំងផ្សេងៗ។ សកម្មភាពទាំងនេះបានរារាំងអ្នកភូមិកម្ពុជា មិនឱ្យចូលទៅរស់នៅក្នុងផ្ទះសម្បែងរបស់ខ្លួន។

**ដោយអះអាងសារជាថ្មីអំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាចំពោះបទឈប់បាញ់** លោកជំទាវ អ៊ិត សោភា បានអំពាវនាវដល់ប្រទេសម៉ាឡេស៊ីក្នុងនាមជាប្រធានអាស៊ាន និងដៃគូពាក់ព័ន្ធផ្សេងៗទៀត ឱ្យពន្លឿនការ**បង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT)** ជាពិសេសតាមរយៈការបញ្ចប់ឱ្យបានឆាប់នៃលក្ខខណ្ឌប្រតិបត្តិ (TOR)។ លោកជំទាវបានថ្លែងអំណរគុណដល់ប្រទេសម៉ាឡេស៊ីសម្រាប់តួនាទីបុរេសកម្ម ក្នុងកិច្ចការនេះ និងបានគូសបញ្ជាក់អំពីជំហរជាគោលការណ៍របស់កម្ពុជាដែលថា **ពុំមានព្រំដែនអន្តរជាតិណាត្រូវបាន**



អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

**ផ្លាស់ប្តូរដោយការប្រើប្រាស់កម្លាំងនោះទេ** ព្រមទាំងបានជំរុញដល់ប្រទេសថៃឱ្យគោរព និងអនុវត្តឱ្យបានពេញលេញនូវកិច្ចព្រមព្រៀងបទឈប់បាញ់នេះ និងដោះស្រាយវិវាទព្រំដែន ដោយផ្អែកតាមច្បាប់អន្តរជាតិ។

លោកជំទាវ អ៊ិត សោភា **បានបដិសេធដាច់អហង្ការលើការចោទប្រកាន់ទាំងឡាយ**ដែលថា កម្ពុជាបានដាក់មីនថ្មី ដោយបានបញ្ជាក់ឡើងវិញពីការប្រកាន់ភ្ជាប់ឥតងាករេរបស់កម្ពុជាចំពោះអនុសញ្ញាអូតាវ៉ា និងការប្តេជ្ញាចិត្តចំពោះសន្តិភាពយូរអង្វែង។ លោកជំទាវបានអះអាងអំពីការត្រៀមខ្លួនរបស់កម្ពុជា ដើម្បីចាប់ផ្តើម**ប្រតិបត្តិការដោះមីនរួមគ្នា**ជាមួយប្រទេសថៃ នៅតំបន់ដែលមានខណ្ឌសីមាច្បាស់លាស់ ឬតំបន់មិនមានវិវាទ ដោយសង្កត់ធ្ងន់ថា នៅតំបន់មានវិវាទ **ការអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពចំពោះកិច្ចព្រមព្រៀងបទឈប់បាញ់ កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២៥ និងកំណត់ហេតុនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មការព្រំដែនទូទៅកម្ពុជា-ថៃ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០២៥** គឺមានភាពចាំបាច់។ ការណ៍នេះមានសារៈសំខាន់ណាស់សម្រាប់ធានាបាននូវសន្តិភាព និងស្ថេរភាព និងសម្រាប់បង្កើតលក្ខខណ្ឌចាំបាច់នានា សម្រាប់គណៈកម្មការចំរុះកិច្ចការព្រំដែនស្តីពីការខ័ណ្ឌសីមាព្រំដែនគោក បន្តការងាររបស់ខ្លួននៅលើដីជាក់ស្តែង។

លោកជំទាវ អ៊ិត សោភា ក៏បានគូសបញ្ជាក់ពីលទ្ធផលនៃ**កិច្ចប្រជុំពិសាតែ** ដែលបានរៀបចំធ្វើនៅក្រៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាង កាលពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២៥ នៅទីក្រុងអាននីង ខេត្តយូណាន ប្រទេសចិន ដែលមានការចូលរួមពីរដ្ឋមន្ត្រីការបរទេសកម្ពុជា ចិន និងថៃ។ ក្នុងកិច្ចប្រជុំនេះ កម្ពុជានិងថៃ បានអះអាងសារជាថ្មីអំពីការប្តេជ្ញាចិត្ត ក្នុងការលើកកម្ពស់ការចូលរួម ធ្វើឱ្យប្រសើរឡើងនូវការទំនាក់ទំនង និងធ្វើការងារឆ្ពោះទៅរក**ការបន្តនៃទំនាក់ទំនងជាប្រក្រតីដូចកាលពីដំបូង** និងការស្តារស្ថេរភាពតាមបណ្តោយព្រំដែន។ លោកជំទាវបានសម្តែងអំណរគុណដល់ប្រទេសចិន ចំពោះការកោះប្រជុំដ៏មានសារៈសំខាន់នេះ និងចំពោះការប្តេជ្ញាចិត្តរបស់ចិន ក្នុងការបន្តដើរតួនាទីស្ថាបនា ជាពិសេសការជួយដល់**ការដោះមីននៅតាមតំបន់ព្រំដែន** ដែលឯកភាពដោយប្រទេសកម្ពុជា និងថៃ។

នេះគឺជា**កិច្ចប្រជុំសង្ខេបព័ត៌មានផ្លូវការលើកទី៣** ដែលរៀបចំដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជូនអង្គទូតបរទេស និងភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា នៅក្នុងគោលបំណងជម្រាបជូនអំពីការវិវត្តថ្មីៗ អំពីសភាពការណ៍តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

ថ្ងៃអាទិត្យ ៨រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០២៥